# សង្កាត់សាលារៀនអូកឡិនដ៍
## ក្រុមប្រឹក្សាភិបាល
## សេចក្ដីជូនដំណឹងអំពីសវនាការសាធារណៈ

## ស្ដីអំពីការមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀនគ្រប់គ្រាន់
## សម្រាប់ឆ្នាំសិក្សា 2021-2022

**ជូនចំពោះភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស គឺមាតាបិតា លោកគ្រូ-អ្នកគ្រូ មេដឹកនាំនៃអង្គភាពខាងចរចារគ្នា និងសមាជិកនៃសហគមន៍ ដែលមានចំណាប់អារម្មណ៍ទៅលើការងារនានានៃសង្កាត់សាលារៀនអូកឡិនដ៍។**

**សូមកត់សំគាល់ថា នៅថ្ងៃទី 22 ខែកញ្ញា ឆ្នាំ 2021** នៅក្នុងកិច្ចប្រជុំធម្មតានៃក្រុមប្រឹក្សាភិបាល ("ក្រុមប្រឹក្សា") នៃសង្កាត់សាលារៀនអូកឡិនដ៍ ក្រុមប្រឹក្សានឹងបើកអង្គប្រជុំជាសាធារណៈមួយ ស្ដីអំពីការមានសៀវភៅសិក្សា និងសម្ភារៈបង្រៀន[1] គ្រប់គ្រាន់ នៅវេលាម៉ោង 7 យប់ ឬបើកយ៉ាងឆាប់បន្ទាប់ពីវេលាហ្នឹង — សំរាប់ឆ្នាំសិក្សា 2021-2022 តាមរយៈអ៊ិនធឺណិត (តាមកម្មវិធី Zoom និង Granicus Live Manager ក្នុងពេលដំណាលគ្នា)។ បន្ទាប់ពីការបញ្ចប់សវនការមក ក្រុមប្រឹក្សាភិបាលត្រូវធ្វើការកំណត់ តាមសេចក្ដីសម្រេច ដូចមានចុះជូននៅក្នុងប្រការ (ក), (ខ) និង (គ) ខាងក្រោមនេះ។

ក្រមអប់រំលេខ 60119 តម្រូវអោយក្រុមប្រឹក្សាភិបាល បើកសវនាការជាសាធារណៈមួយ ក្នុងរយៈពេលសាលាបើកឱ្យសិស្សចូលរៀនបានប្រាំបីសប្ដាហ៍ដំបូង ដើម្បីធ្វើការកំណត់៖

(ក) ថាតើសិស្សម្នាក់ៗ នៅក្នុងសាលារៀននីមួយៗរបស់សង្កាត់ មានសៀវភៅសិក្សា ឬមានសម្ភារៈបង្រៀនគ្រប់គ្រាន់ ឬមានទាំងពីរ ដែលស្របតាមស្តង់ដារមាតិកា ដែលបានអនុម័តដោយក្រុមប្រឹក្សា [អប់រំ] ថ្នាក់រដ្ឋ នៅក្នុងមុខវិជ្ជានីមួយៗដូចតទៅនេះ តាមដែលសមស្របដែលត្រូវនឹងមាតិកា និងខួបរបស់គំរោងនៃកម្មវិធីសិក្សា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៃរដ្ឋកាលីហ្វូនញ៉ា៖

- គណិតវិទ្យា,
- វិទ្យាសាស្ត្រ,
- ប្រវត្តិវិទ្យា-សង្គមវិទ្យា,
- ភាសាវិទ្យាអង់គ្លេស រួមទាំងសមាសភាគអភិវឌ្ឍន៍ភាសាអង់គ្លេសនៃកម្មវិធីដែលបានអនុម័ត; និង

(ខ) ថាតើសិស្សម្នាក់ៗដែលបានចុះឈ្មោះចូលរៀនថ្នាក់ភាសាពិភពលោក ឬថ្នាក់សុខភាព មានសៀវភៅសិក្សា ឬមានសម្ភារៈបង្រៀនគ្រប់គ្រាន់ ដែលស្របតាមស្តង់ដារនៃមាតិកា និងខួបរបស់គំរោងនៃកម្មវិធីសិក្សា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលថ្នាក់រដ្ឋ សំរាប់មុខវិជ្ជាទាំងនោះ; និង

(គ) ការមានប្រដាប់ប្រដារគ្រប់គ្រាន់សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត ដែលជាប់ទាក់ទងទៅនឹងថ្នាក់អនុវត្តវិទ្យាសាស្ត្រ ដែលបានផ្ដល់អោយសិស្សទាំងអស់ដែលរៀងថ្នាក់ទី 9 ដល់ទី 12។

**សេចក្ដីសម្រេច និងរបាយការណ៍ (តាមការរកឃើញនានា) ដែលបានដាក់ស្នើសុំមួយច្បាប់ ស្ដីអំពីការមានសៀវសិក្សា និងសម្ភារៈបង្រៀនគ្រប់គ្រាន់ នៃឆ្នាំ សិក្សា 2021-2022 របស់សង្កាត់ គឺមានដាក់ជូនសម្រាប់ធ្វើការពិនិត្យមើល តាមរយៈ World Wide Web (វើលវ៉ាយវិប) នៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 2021 នៅគេហទំព័រ៖** [http://www.ousd.org/domain/69](http://www.ousd.org/domain/69)។

s/Kyla Johnson Trammell
លេខាធិការនៃក្រុមប្រឹក្សាភិបាល
សង្កាត់សាលារៀនអូកឡិនដ៍

---

[1] ការមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀនគ្រប់គ្រាន់ មានន័យថា សិស្សម្នាក់ៗ រួមទាំងសិស្សអ្នករៀនអង់គ្លេសដែរ គឺមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀន ស្របតាមស្តង់ដារ ឬមានទាំងពីរ ដើម្បីប្រើប្រាស់នៅក្នុងថ្នាក់រៀន និងយកទៅផ្ទះ។ [វា] អត់តម្រូវឱ្យមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀនពីរឈុត ឬមានទាំងពីរប្រភេទ ដើម្បីប្រើប្រាស់នៅក្នុងថ្នាក់រៀន ឬនៅឯផ្ទះទេ។ ក្រមអប់រំផ្នែកទី 60119(c)(1)។